# *អេនជីស៍ កើតឆ្នាំ១៩៤១*

រូបខ្ញុំស្ថិតនៅក្នុងក្រុមនៃមនុស្សស្រលាញ់ភេទដូចគ្នាជាច្រើននាក់ ដែលមិនហ៊ានបង្ហាញចេញឲ្យគេដឹងជាចំហរឡើយ នៅពេលពួកគេនៅក្មេង ប៉ុន្តែជំនួសមកវិញ នៅទីបំផុត បែរបានរៀបការ និងមានកូន។ នៅពេលខ្ញុំដឹងថាត្រង់នេះតើវាខុសបែបម៉េចនោះ ឧបសគ្គដែលនឹងត្រូវជម្នះជាបន្តបន្ទាប់មានទំហំធំសម្បើម តែមិនថ្មីឡើយ ជីវិតគឺជាការសប្បាយ។ តើខ្ញុំនឹងហ៊ានទាក់ទងមនុស្សស្រលាញ់ភេទដូចគ្នាផ្សេងទៀតដែរឬទេ? ដោយវិធីណា និងនៅទីកន្លែងណា?

ហើយកាលពីថ្ងៃចុងសប្តាហ៍មួយនោះ ប្រពន្ធរបស់ខ្ញុំបានសម្រេចចិត្តនាំកូនៗទៅលេងមិត្តជិតស្និទរបស់នាងដែលរស់នៅឃ្លាតពីហ្នឹងចម្ងាយ ១០០ គីឡូម៉ែត្រ។ ខ្ញុំគួរតែនៅផ្ទះព្រោះចៀមត្រូវការឲ្យចំណី និងស្រោចទឹក។ ដូច្នេះក្រុមគ្រួសារខ្ញុំក៏បានចាកចេញទៅ ហើយខ្ញុំក៏បានស្រវាចាប់យកទូរសព្ទភ្លាម និងបានឃើញថាមានពិធីជប់លៀង LGBT មួយនៅឯទីក្រុងយប់នោះ។ ខ្ញុំបានរាវែក គិត និងសម្រេចចិត្តថា ទេ ខ្ញុំនឹងមិនទៅទេ ប៉ុន្តែបីវិនាទីក្រោយមក ខ្ញុំក៏ថា ទៅ វិញ ហើយក៏នៅបន្តអូសបន្លាយចុះឡើងបែបហ្នឹងរាប់ម៉ោង។

ចុងបញ្ចប់ ខ្ញុំក៏សម្រេចថាទៅ។ ដូច្នេះខ្ញុំក៏ជិះឡានទៅទីក្រុង ហើយចតនៅឃ្លាតពីហ្នឹងបីអគារ។ បន្ទាប់ពីដើរជុំវិញអគារនោះបីជុំ ខ្ញុំក៏បានបើកទ្វារចូល ហើយដើរទៅត្រង់យ៉ាងលឿន។ គ្រាន់តែគិតមើលទៅថា ខណៈបេះដូងកំពុងលោតដុកដាក់ៗ បើខ្ញុំនៅត្រូវរង់ចាំមួយឬក៏ពីរនាទីទៀតនោះ តើមនុស្សប៉ុន្មាននាក់ដែលនឹងបានឃើញខ្ញុំ? ប៉ុន្តែបើនិយាយតាមត្រង់ទៅ ទីតាំងនោះគឺជាកន្លែងដាច់ស្រយាល ហើយឱកាសដែលមនុស្សចេញតាមផ្លូវនេះនៅថ្ងៃសៅរ៍ ពេលយប់ម៉ោង៩ គឺតិចតួចណាស់។

នៅទីនោះ ខ្ញុំបានជួប អេនជីស៍ ដែលបានរៀនក្នុងថ្នាក់ជាមួយខ្ញុំកាលនៅសាលារៀន។ គាត់ជាមនុស្សម្នាក់ស្រលាញ់ភេទដូចគ្នាដោយបើកចំហ ដែលជាសមាជិកនៃគណៈគ្រប់គ្រងនៃ RFSL (សហព័ន្ធស៊ុីសដើម្បីសិទ្ធិស្ត្រីស្រលាញ់ស្ត្រីដូចគ្នា មនុស្សស្រលាញ់ភេទដូចគ្នា ខ្ទើយ និងមនុស្សកែភេទ) ហើយបច្ចុប្បន្នគេមិនមានមិត្តប្រុសទេ។ ដូច្នេះ ប្រាកដ

ណាស់ ខ្ញុំក៏បានទៅផ្ទះជាមួយគាត់។ ហើយព្រឹកឡើង គាត់បានមកផ្ទះជាមួយខ្ញុំ ដើម្បីជួយមើលសត្វចៀម។

បន្ទាប់ពីថ្ងៃចុងសប្តាហ៍នោះ ខ្ញុំបានចាប់ផ្តើមចេញពីធ្វើការយឺតមួយល្ងាចក្នុងមួយសប្តាហ៍ ដោយត្រូវទទួលបន្ទុកធ្វើកិច្ចការស្រាវជ្រាវមួយ។ ប៉ុន្តែគ្រប់យ៉ាងទាំងអស់ដែលខ្ញុំកំពុងធ្វើការស្រាវជ្រាវនោះគឺអំពី អេនដឺស៍។ ខ្ញុំសប្បាយរីករាយ ហើយប្រពន្ធរបស់ខ្ញុំបានកត់សម្គាល់ឃើញ និងបានសួរថា ហេតុអ្វី។ ខ្ញុំឥឡូវនេះដូចជារញ៉េរញ៉ៃណាស់។ ខ្ញុំបាននិយាយប្រាប់ការពិតមួយផ្នែកថា ខ្ញុំបានជួបមិត្តភ័ក្ត្ររួមសាលាម្នាក់ ដែលធ្លាប់ជួយខ្ញុំធ្វើសំណេរ។ នាងគិតថា វាជាការណ៍ល្អដែលគួរតែជួបគាត់។ ដូច្នេះពេលរសៀលថ្ងៃមួយចំថ្ងៃសៅរ៍ គាត់បានអញ្ជើញគ្រួសារទាំងមូល ដើម្បីទទួលទានកាហ្វេ។

អេនដឺស៍ និង អេវ៉ា បានដឹងថា ពួកគេទាំងពីរនាក់ចូលចិត្តរបាំប្រជាប្រិយ (ដែលខ្ញុំមិនចូលចិត្ត) ហើយមួយរំពេចនោះ ពួកគេបានសម្រេចចិត្តទៅរៀនជាមួយគ្នា។ ទីបំផុត គឺជារូបខ្ញុំដែលត្រូវយកកូនៗទៅគេងលើគ្រែ នៅពេលដែលពួកគេកំពុងនៅរៀនជាមួយគ្នា និងបន្ទាប់មកត្រៀមរៀបចំនំសាំងវិចនិងតែឲ្យរួចរាល់ នៅពេលដែលពួកគេបានមកផ្ទះនៅពេលបន្ទាប់។

ហើយ ពិតណាស់ ក៏ចាប់ផ្តើមមានពាក្យចចាមរាមថា អេវ៉ា មានប្រុសនៅក្បែរខ្លួន។ អីក៏ស្រណុកស្រួលម្ល៉េះ! ប៉ុន្តែតើនឹងមានអ្វីកើតឡើង ប្រសិនបើមនុស្សម្នាបានដឹងថា គាត់ជាមនុស្សជាទីស្រលាញ់របស់ខ្ញុំ ហើយមិនមែនជាមនុស្សរបស់ អេវ៉ា នោះ? មានតែមនុស្សម្នាក់ទៀតប៉ុណ្ណោះដែលបានដឹងរឿងនោះគឺ គ្រូបង្ហាត់របាំប្រជាប្រិយ ដែលជាសមាជិកនៃគណៈគ្រប់គ្រងនៃ RFSL ដែរ។

ដូច្នេះហើយ តើមានអ្វីបានកើតឡើង? គឺការលែងលះ ខ្ញុំត្រូវបានណែនាំឲ្យម្តាយរបស់អេនដឺស៍ បានស្គាល់។ ហើយក្រោយមក ព្រឹកថ្ងៃមួយ អេនដឺស៍ ត្រូវបានដឹងថាបានស្លាប់ដោយសារជំងឺគាំងបេះដូង...។